មេរៀនទី ១

# ភ្នំដូនពេញ



វត្តភ្នំដូនពេញ ស្ថិតនៅ
កណ្ដាលរាជធានីភ្នំពេញ ។

## ពណ៌នាអំពីភ្នំដូនពេញ

*ចូរអានការសន្ទនារវាងឪពុក និង កូនអំពីវត្តភ្នំដូនពេញ ។*



ឪពុក : នេះគឺវត្តភ្នំដូនពេញ ។ ភ្នំនេះកើតឡើងដោយសារដូនពេញនាំអ្នកស្រុកពូនដី ។

កូន : គួរសរសើរមែន ! នៅជើងភ្នំមានសួនច្បារ និងដើមឈើធំៗ ពុក ! ជណ្ដើរនេះទៅដល់ណា ?

ឪពុក : ទៅព្រះវិហារនិងព្រះចេតិយ ។ កូនមើលនោះ! ព្រះចេតិយនៅខាងលើភ្នំ ។

កូន : ពុក ! ព្រះចេតិយនោះធំមែនទែន ។ តើកន្លែងនោះសំរាប់ធ្វើអ្វី ?

ឪពុក : សំរាប់តំកល់ព្រះអដ្ឋិធាតុព្រះបាទពញាយ៉ាត ។

## លំហាត់សន្ទនា

ក. *ចូរឆ្លើយនឹងសំនួរខាងក្រោមនេះ ។*

១. តើអ្នកណាខ្លះ ពូនភ្នំនេះឡើង ?

២. តើនៅភ្នំដូនពេញ មានអ្វីខ្លះ ?

៣. តើគេតំកល់អ្វីនៅក្នុងព្រះចេតិយ ?



ខ. *ចូររៀបរាប់ទីកន្លែងកំសាន្តដែលអ្នកធ្លាប់ស្គាល់ ។*

គ. *ចូរពណ៌នារូបភាពខាងស្តាំនេះ ។*

## អំនាន

*ចូរអានអត្ថបទនៅទំព័រទី ១២៩ រួចឆ្លើយនឹងសំនួរ ។*



# ភ្នំដូនពេញ

ដូនពេញ ជាស្ត្រីចំនាស់ម្នាក់ ។ ថ្ងៃមួយ គាត់រើសបានព្រះពុទ្ធរូបបួនអង្គ ពីក្នុងដើមគគីរ ដែលអណ្តែតតាមទឹកទន្លេមេគង្គ មកទើរនឹងច្រាំងទន្លេ ក្បែរកន្លែងរបស់គាត់រស់នៅ ។

ដូនពេញបាននាំអ្នកស្រុកជញ្ជូនដី ពូនជាកូនភ្នំមួយនិងកសាងព្រះវិហារ ដើម្បីតំកល់ព្រះពុទ្ធរូបទាំងនោះ ។

អ្នកស្រុកបាននាំគ្នាហៅទីនោះថា វត្តភ្នំដូនពេញ ។ ក្រោយមករាជធានីនៃប្រទេសកម្ពុជាយើង មានឈ្មោះថា ភ្នំពេញ ។

## ? សំនួរត្រិះរិះ

១. តើដូនពេញ រើសបានអ្វីពីក្នុងដើមគគីរ ?

២. តើដូនពេញ យកព្រះពុទ្ធរូបទាំងនោះ ទៅតំកល់ទុកនៅឯណា ?

៣. តើវត្តដែលដូនពេញ និងអ្នកស្រុកបានសាងឡើងឈ្មោះវត្តអ្វី ?

៤. តើរាជធានីប្រទេសកម្ពុជាយើង ឈ្មោះអ្វី ?

## លំហាត់សរសេរ

*ក.* *ចូរចំលងកន្សោមពាក្យខាងក្រោម អោយបានត្រឹមត្រូវ ។*

ព្រះពុទ្ធរូប ព្រះវិហារ ទន្លេមេគង្គ រាជធានីភ្នំពេញ ។

*ខ.* *ចូរតែងល្បះតាមរូបភាពខាងក្រោមនេះ ។*

